**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ: ៣៣៤ /អយក.ហវ

ថ្ងៃចន្ទ ៥ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៥

## ជម្រាបជូន

- **ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
- **ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**
- **លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ ៖ ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍» ជូនអង្គភាពថវិកាថ្នាក់រដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីឆ្នាំ២០២៥ នេះតទៅ។

យោង ៖ ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៥ របស់នាយកដ្ឋានហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា៖ ក្រសួងបានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលមានលក្ខណៈជា Web Application (Online) បញ្ចប់សព្វគ្រប់ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រងហិរញ្ញប្បទានគ្រប់ប្រភពថវិកាពីដៃគូអភិវឌ្ឍន៍ដែលជួយគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យការរៀបចំ និងគ្រប់គ្រងហិរញ្ញប្បទានកាន់តែមានសុក្រឹតភាព គណនេយ្យភាព និងប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅនឹងនីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ (SOP) របស់រាជរដ្ឋាភិបាលកម្ពុជា ដោយប្រព័ន្ធមានសមត្ថភាពក្នុងការបង្កលក្ខណៈងាយស្រួល ជូនអ្នកប្រើប្រាស់សម្រាប់ការរើកាជថវិកា ការកត់ត្រាចំណូល ចំណាយ ការផលិតកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗ ដែលមានលក្ខណៈជាស្វ័យប្រវត្តិកម្ម ជាពិសេសស្របជាមួយនឹងសារាចរណែនាំស្តីពីការបិទបញ្ជីចំណូល-ចំណាយថវិកា និងរបាយការណ៍បូកសរុបការអនុវត្តចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំឆ្នាំ និងស្តង់ដាគណនេយ្យរបស់ជាតិ។ ក្នុងន័យនេះ ក្រសួងសូមដាក់ឱ្យប្រើប្រាស់



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) លើមុខងារគ្រប់គ្រងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជូនអង្គភាពថវិកាថ្នាក់រដ្ឋបាលកណ្ដាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តចាប់ពីឆ្នាំ ២០២៥ នេះតទៅ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ